# ថ្វាយបង្គំ ជម្រាបសួរ

# បងប្អូនទាំងអស់គ្នា!



# សិទ្ធិ និងករណីកិច្ចការពារបរិស្ថាន

# ធនធានធម្មជាតិនៅកម្ពុជា

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ឧសភា ឆ្នាំ២០២៣

## ពញ្ញាក់ស្មារតី ១០នាទី៖



២. ចូលបង្ហាញទស្សនវិសយរបស់អ្នក ចំពោះសង្គមកម្ពុជាដែលអ្នកចង់បាន ក្នុងរយៈពេល **៥ឆ្នាំបន្ទាប់។**

២. បង្ហាញពីការប្តេជ្ញាចិត្តរបស់ ក្នុងការជំរុញ ឬធ្វើឱ្យទស្សនវិសយដែលអ្នក បានសម្រេច ។ (៥នាទី)





# មាតិកាសម្រាប់ការចែករំលែក៖

១. និយមន័យទូទៅសិទ្ធិ ករណីកិច្ច បរិស្ថាន ធនធានធម្មជាតិ

២. ឋានានុក្រមនៃច្បាប់

៣. ច្បាប់ និងគោលនយោបាយ គ្រប់គ្រងធនធានធម្មជាតិ

៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រងការពារធនធានធម្មជាតិ

៥. គោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលការពារធនធានធម្មជាតិ

៦. ស្ថានភាពធនធានធម្មជាតិ នៅកម្ពុជា

៧. ផ្សេងៗ







# ១. និយមន័យទូទៅ នៃសិទ្ធិ ន័យទូទៅ៖

**សិទ្ធិ** (ន) មានន័យថា សេចក្ដីសម្រេច, សេចក្ដីសម្រេចផល ឬផលសម្រេច, ការសម្រេចប្រយោជន៍, ការដាច់ស្រេច, ការសមប្រកប, ការសមតាមបំណង, សេចក្ដីសុខសេចក្ដីចម្រើន, សេចក្ដីស័ក្ដិសិទ្ធិ, សេចក្ដីខ្លាំងពូកែ, សេចក្ដីសម្បូរណ៍, សេចក្ដីសម្រេចតាមអំណាចច្បាប់, អំណាច, សេចក្ដីអង់អាច ។

(វចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជ ជួន ណាត)។








# »ត. ១. និយមន័យទូទៅ នៃសិទ្ធិ ក្នុងន័យសិទ្ធិមនុស្ស៖




**សិទ្ធិ** គឺជាការទាមទារអំណាច ឬជាការប្រគល់អំណាចនូវអ្វីគ្រប់យ៉ាងដែលមនុស្សជឿថាគេត្រូវមាន និងគួរតែមាន ។

(សិទ្ធិក្នុងន័យសិទ្ធិមនុស្ស) ។



# »ត. ១. និយមន័យទូទៅ ករណីកិច្ចៈ








**ករណីកិច្ច** ( ន ) កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ ។

(វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន ណាត )។

## រណីយកិច្ច និង កាតព្វកិច្ច

គឺសំដៅលើកិច្ចការ ដែលត្រូវតែធ្វើជាចាំបាច់ ដោយមិនអាចរំលងបានឡើយ។ ឧទាហរណ៍៖ កាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ត្រូវតែបង់ពន្ធជូនរដ្ឋកុំបីខាន។

រីឯពាក្យភារកិច្ច ជាកិច្ចការ ដែលចាំចាច់ធ្វើក៏បាន ឬមិនធ្វើក៏បាន។

**ឧទាហរណ៍**៖ ហាមចូល បើគ្មានភារកិច្ច។l

https://bit.ly/3TvYXHa *(thmeythmey)*

# ១. និយមន័យទូទៅ ពីបរិស្ថាន៖

**បរិស្ថាន** មានន័យថា អ្វីៗដែលនៅជុំវិញខ្លួនយើង និងខ្លួនយើងផងដែរ រាប់ទាំងភាវៈមានជីវិត និងគ្មានជីវិត ។

ភាវៈមានជីវិត និងគ្មានជីវិតទាំងអស់នៅលើផែនដីមានទំនាក់ទំនងនឹងគ្នា ហើយអាចជះឥទ្ធិពលគ្នាទៅវិញទៅមកដោយផ្ទាល់ និងប្រយោល ។



## ក». បរិស្ថាន ចែកចេញជាពីរផ្នែក គឺ

## ទី១. បរិស្ថានធម្មជាតិ និង ទី២.បរិស្ថានសង្គម ។

**ទី១. បរិស្ថានធម្មជាតិ** គឺ ជាអ្វីៗដែលមាននៅលើភពផែនដី ដែលមិនមែនបង្កើតឡើងដោយមនុស្ស ។ ក្នុងនោះរួមមាន ភាវៈមានជីវិតទាំងអស់ ដូចជារុក្ខជាតិ និងសត្វ ហើយភាវៈគ្មានជីវិតទាំងអស់ ដែលភាវៈមានជីវិតពឹងផ្អែកទៅលើ ដូចជា ទឹក ដី ភ្លើង និងខ្យល់ ។

**ឧទាហរណ៍៖** រុក្ខជាតិ ពឹងផ្អែកទៅលើទឹក និងដី ។

**ទី២. បរិស្ថានសង្គម** ចែកជា៖ **១. បរិស្ថានវប្បធម៌** និងបរិស្ថានវប្បធម៌ និងបរិស្ថាន គឺមានទំនាក់ទំនងនឹងគ្នាយ៉ាងខ្លាំង ធនធានធម្មជាតិ អាកាសធាតុ ទេសភាព ជះឥទ្ធិពលទៅការរស់នៅ ជីវិត និងជំនឿរបស់មនុស្ស ។ នៅពេលដែលបរិស្ថានមានការប្រែប្រួល នោះវប្បធម៌ក៏អាចនឹងត្រូវទទួលរងនូវភាពប្រេះស្រាំ និងបំផ្លាញដែរ ។

**ឧទាហរណ៍៖** សហគមន៍ខ្លះ **មានព្រៃអារក្ស** ដែលត្រូវបានគេគោរពបូជាជាពិសេស ។ ប៉ុន្តែពេលដែលព្រៃឈើទាំងនោះត្រូវបាន**ក្រុមហ៊ុនរកស៊ីកាប់ឈើធំៗមកធ្វើវិនិយោគ** ប្រជាជនជាច្រើនដែលធ្លាប់ពឹងផ្អែកលើការប្រមូលផល អនុផលព្រៃឈើ បានប្ដូរមុខរបរទៅធ្វើជាកម្មករវិញ ។ ការអភិវឌ្ឍបែបនេះ *អាចកែប្រែវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនក្នុងសហគមន៍មួយបាន* ។ ប្រជាជនដែលរស់នៅក្នុងសហគមន៍នោះអាចឈប់គោរព និងលែងមានជំនឿទៅទៀតហើយ ។







# ២. បរិស្ថាន ដែលបង្កើតឡើងដោយមនុស្ស

**បរិស្ថានដែលបង្កើតឡើងដោយមនុស្ស** រួមមានអ្វីៗទាំងអស់ដែលមនុស្សកែច្នៃ ឬផលិតឡើង ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន ដូចជា ចំណីអាហារ ទីជម្រក និងសម្លៀកបំពាក់ ។

លើសពីនោះទៀតមានរបស់ដែលមនុស្សបង្កើត ដូចជា សាលារៀន មន្ទីរពេទ្យវត្តអារាម ស្ពាន ថ្នល់ និងវត្ថុផ្សេងៗទៀត ។





# ស្ដាប់ទាន់ខ្លះទាន!



# ព្យុះតំនិត

## សាកល្បងឱ្យនិយមន័យពី «ធនធានធម្មជាតិ» តាមការយល់ឃើញរបស់អ្នក ។



# »គ. ១. និយមន័យទូទៅពី ធនធានធម្មជាតិ

ធនធានធម្មជាតិ គឺជាធនធានដែលយកចេញពីផែនដីត្រូវបានប្រើប្រាស់ដោយមនុស្ស ហើយអាចកើតឡើដោយឯកឯងពីធម្មជាតិ។

ធនធានធម្មជាតិមាន ខ្យល់ ទឹកសាប ទឹកប្រៃ ដី រ៉ែ រុក្ខជាតិ សត្វ (លើគោក ក្នុងទឹក) ។

ធនធានធម្មជាតិមានពីរ គឺធនធានធម្មជាតិកើតឡើងវិញ និង ធនធានធម្មជាតិមិនកើតឡើងវិញ។

ធនធានធម្មជាតិកើតឡើងវិញ គឺជាធនធានទាំងឡាយណាដែលមានជានិរន្តរ៍ ៗ ធនធានទាំងនោះអាចកើតចេញពីប្រភពដែលមិនចេះរីងស្ងួត ឬកើតមានជាអចិន្ត្រៃយ៍ ដូចជាថាមពលពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ថាមពលចរន្តទឹក..និងថាមពលដែលកើតចេញពីសារពាង្គកាយមានជីវិតដទៃទៀត ៗ ធនធានទាំងនោះ សុទ្ធតែកើតឡើងវិញ ឬអាចកើតឡើងវិញបាន ៗ





**ធនធានធម្មជាតិមិនកើតឡើងវិញ** គឺជាធនធានទាំងឡាយណាដែលអាចប្រើប្រាស់ដល់កម្រិតមួយដែលគេមិនអាចទាញយកមកប្រើប្រាស់ទៀតបាន ។ ធនធានមួយចាប់ផ្ដើមហិនហោច និងខ្សត់នៅពេលដែលធនធាននោះត្រូវគេបើប្រាស់អស់ ។



ធនធានធម្មជាតិមិនកើតឡើងវិញ មានរ៉ែ លោហៈ (ដែក សំណ ស័ង្កសី មាស...) រ៉ែអលោហៈ (ដូចជា ត្បូង ស្ពាន់ធ័រ...) ខ្សាច់ ដីឥដ្ឋ ធនធានថាមពល (ប្រេងកាត ឧស្ម័នធម្មជាតិ ធ្យូងថ្ម) ។



# យល់ ឬមិនយល់?

## ឧកឧត្តម លោកជំទាវ



# ២. ឋានុក្រមនៃច្បាប់

- ច្បាប់រដ្ឋធម្មនុញ្ញ
  - ច្បាប់អន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិ
    - ច្បាប់ជាតិ
      - រាជក្រឹត្យ
        - អនុក្រឹត្យ
          - ប្រកាស
            - សារាចរ

# »គ. ២. ឋានានុក្រមនៃច្បាប់កម្ពុជា

- ច្បាប់រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូល និង ជាប្រភពនៃច្បាប់នៅក្នុងប្រទេសកម្ពុជា ។
- ច្បាប់ ៖ ត្រូវបានអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រឬប្រមុខរដ្ឋស្តីទី ច្បាប់នីមួយៗ ត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញដាច់ខាត ។
- ព្រះរាជក្រឹត្យ ៖ ចេញដោយព្រះមហាក្សត្រសម្រាប់ធ្វើការអនុវត្តន៍នូវសិទ្ធិអំណាចរបស់ព្រះអង្គ តាមដែល រដ្ឋធម្មនុញ្ញបានកំណត់ ហើយព្រះរាជក្រឹត្យ ត្រូវតែស្របរដ្ឋធម្មនុញ្ញដាច់ខាត ។
- អនុក្រឹត្យ ៖ ត្រូវបានអនុម័តយល់ព្រមដោយគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី អនុក្រឹត្យនីមួយៗ ត្រូវតែស្របទៅនឹងរដ្ឋធម្មនុញ្ញ និងស្របជាមួយច្បាប់ដែលអនុក្រឹត្យនោះត្រូវចេញ ។
- ប្រកាស ៖ គឺជាសេចក្តីសម្រេចរបស់ក្រសួង ឬអន្តរក្រសួង ហើយចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ហើយប្រកាសត្រូវតែស្របជាមួយនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ អនុក្រឹត្យ ដែលប្រកាសនោះចេញ ។
- សារាចរ ៖ គឺជាលិខិតបទដ្ឋានដែលក្រសួង ឬអាជ្ញាធរថ្នាក់ខ្ពស់ណាមួយ ប្រើប្រាស់ដើម្បីធ្វើការបំភ្លឺទៅលើចំណុចខ្លះក្នុងច្បាប់ ផ្តល់សេចក្តីណែនាំ សារាចរគ្រាន់តែជាការផ្តល់យោបល់ប៉ុណ្ណោះ ហើយវាមិនមានអានុភាពគតិយុត្តិអ្វីឡើយ ។

https://bit.ly/3CZ3AE9 (camdc.wordpress.com)



# ក្លីខ្លះអក់?

## កុមារា កុមារី

## លោកបង លោកប្អូន!

# ៣. ច្បាប់ និងគោលនយោបាយ គ្រប់គ្រងធនធានធម្មជាតិ

រដ្ឋធម្មនុញ្ញ
ឆ្នាំ១៩៩៣

ច្បាប់ស្តីពី កិច្ចគាំពារបរិស្ថាន និងការការពារធនធានធម្មជាតិ

ឆ្នាំ១៩៩៦




ឆ្នាំ២០០២



ឆ្នាំ ២០០៨

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២

ឆ្នាំ ២០០៨




ឆ្នាំ ២០១០

*ប្រភព៖ បទបង្ហាញលោក សាន់ ម៉ាឡា*

# ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

**មាត្រា៣៩.** ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

រដ្ឋធម្មនុញ្ញ
ឆ្នាំ១៩៩៣

# ត. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

**មាត្រា៥៩.** រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

រដ្ឋធម្មនុញ្ញ
ឆ្នាំ១៩៩៣

# ត. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

## គោលដៅ៖ មាត្រា១.

ច្បាប់ស្តីពី
កិច្ចគាំពារបរិស្ថាន
និងការការពារធនធានធម្មជាតិ

ឆ្នាំ១៩៩៦

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតម្លៃហេតុប៉ះពាល់បរិស្ថានមុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះរាល់គម្រោងដែលបានស្នើឡើង
- ធានាឱ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឱ្យសាធារណជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បង្ក្រាបអំពើទាំងឡាយណាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។

# គ.៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

## ជំពូកទី៧. ការចូលរួមរបស់សាធារណជន និងការស្រង់យកព័ត៌មាន

### មាត្រា១៦.

ក្រសួងបរិស្ថានត្រូវផ្តល់ជូនតាមសំណូមពររបស់សាធារណជន នូវព័ត៌មានពីសកម្មភាពរបស់ខ្លួន និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីសាធារណជន ក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

### មាត្រា១៧.

បែបបទនៃការចូលរួមរបស់សាធារណជន និងការស្រង់យកព័ត៌មានក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

# ត. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

**មាត្រា១.** គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌ៗ

**មាត្រា២.** ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី ។ រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើ របស់សហគមន៍មូលដ្ឋាន ក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀតៗ

**មាត្រា៣.** ការគ្រប់គ្រងព្រៃឈើត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៗ




ឆ្នាំ២០០២

# ត. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ




២០០២

**មាត្រា៣២.** ព្រៃឈើត្រូវបានការពារប្រឆាំងនឹងរាល់សកម្មភាពដែលធ្វើឱ្យខូចខាតបណ្តាលមកពីការធ្វើអាជីវកម្មហួសហេតុ ការកាប់រានដីព្រៃដោយរំលោភការបំពុលមជ្ឈដ្ឋានព្រៃឈើ ភ្លើងឆេះព្រៃ ការធ្វើចំការពនេចរ ជម្ងឺ សត្វល្អិតចង្រៃ និងការនាំចូលប្រភេទរុក្ខជាតិ និងសត្វរាតត្បាតៗ (៩ ) បង្កើតមូលដ្ឋានកែឆ្នៃល្លិរមៀត ឬអនុផលព្រៃឈើផ្សេងទៀត ដែលនាំឱ្យការបំពុល ឬបំផ្លាញមជ្ឈដ្ឋានព្រៃឈើៗ

**មាត្រា៣៤.** ការនាំចេញ នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃ ឬប្រភេទរុក្ខជាតិព្រៃត្រូវឆ្លងកាត់ការសិក្សាស្រាវជ្រាវ វាយតម្លៃពីរដ្ឋបាលព្រៃឈើ និងត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទៗ ការនាំចូលគ្រាប់ពូជរុក្ខជាតិគ្រប់ប្រភេទ ត្រូវមានទិដ្ឋការគ្រាប់ពូជ ដែលបញ្ជាក់ដោយអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញៗ

# គ. សិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋ



ឆ្នាំ ២០០៨

**មាត្រា២១.**

សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច សាធារណជន និងសង្គមស៊ីវិល ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងពេញលេញ ក្នុងការផ្តល់ និងការទទួលយកព័ត៌មានទាក់ទងនឹងការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ ។

# ត. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រង ការពារធនធានធម្មជាតិ

**មាត្រា២២.** រដ្ឋទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ ។

សិទ្ធិនេះអាចប្រព្រឹត្តិទៅបានក្នុងតំបន់ប្រើប្រាស់ចីរភាព និងតំបន់អភិរក្សដោយអនុវត្តទៅតាមគោលការណ៍ណែនាំកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។



ឆ្នាំ ២០០៨

# ក. ៤. សិទ្ធិ និងករណីកិច្ចគ្រប់គ្រងការពារធនធានធម្មជាតិ



**មាត្រា ២៩.** ប្រជាពលរដ្ឋ ព្រះសង្ឃ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន មានករណីយកិច្ចចូលរួមការពារ អភិរក្ស និងស្ដារធនធានធម្មជាតិឡើងវិញក្នុងតំបន់ការពារធម្មជាតិ ។



# សិទ្ធិ និងករណីយកិច្ច ចូលរួមការពារធនធានធម្មជាតិ



## សិទ្ធិ និងករណីយកិច្ច រូបវន្តបុគ្គល

- ការចូលរួមកិច្ចការពារ
- សិទ្ធិអាស្រ័យផល អនុផល
- សិទ្ធិធ្វើការតស៊ូមតិ និងចូលរួមតស៊ូមតិ
- សិទ្ធិចូលរួមស្តារឡើងវិញ
- សិទ្ធិទទួលបានការអប់រំ
- សិទ្ធិប្តឹងបរិហារប្រឆាំងសកម្មភាពឧក្រិដ្ឋ
- សិទ្ធិចូលរួមផ្សព្វផ្សាយ ផ្តល់ និងទទួលព័ត៌ម

# ប្រភេទសហគមន៍ នៅក្នុងប្រទេសកម្ពុជា ដែលមានសិទ្ធិ

| | |
|---|---|
| សហគមន៍មូលដ្ឋាន | ជាបណ្តាញ ក្រុមមនុស្សដែលរស់នៅជុំវិញ និងជាអ្នកអាស្រ័យផលអនុផលដោយផ្ទាល់ពីព្រៃ |
| សហគមន៍តំបន់ការពារធម្មជាតិ | ជាសហគមន៍មានកិច្ចព្រមព្រៀងទទួលស្គាល់ពីក្រសួងបរិស្ថាន ដើម្បីទទួលបានការថែទាំនៅផ្នែកណាមួយនៃតំបន់ប្រើប្រាស់ដោយចីរភាព នៃតំបន់ការពារធម្មជាតិ ។ |
| សហគមន៍ព្រៃឈើ | ជាសហគមន៍មានកិច្ចព្រមព្រៀងជាមួយរដ្ឋបាលព្រៃឈើ ដើម្បីទទួលបានការថែទាំនៅផ្នែកណាមួយនៃតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ |
| សហគមន៍ជនជាតិដើមភាគតិច | ជាសហគមន៍ដែលមានការទទួលស្គាល់ លើលក្ខណៈឯកភាពនៃជាតិពន្ធ ដោយមានការទទួលពីក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ ។ |
| សហគមន៍អេកូទេសចរណ៍ | ជាសហគមន៍ទេសចរណ៍បែបធម្មជាតិ ដែលមានភាគច្រើនមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្រដែលមានធម្មជាតិ អភិរក្ស ជាដើម។ |

ប្រាប់តាមត្រង់
ធុញហើយទៅ!



# ៥. គោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលការពារធនធានធម្មជាតិ

## យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ឆ្នាំ២០០៨៖ មុំទី៤. កំណែទម្រង់ព្រៃឈើ

សាស្ត្រចតុកោណ
ណាក់កាលទី២

ឆ្នាំ ២០០៨

**៥៨.** គោលនយោបាយព្រៃឈើរបស់រាជរដ្ឋាភិបាល គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងការប្រើប្រាស់ធនធានព្រៃឈើ សម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ និងចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ ។ កន្លងមក រាជរដ្ឋាភិបាល បានផ្អាកការធ្វើអាជីវកម្មឈើ បង្កើតតំបន់ការពារ និងអភិរក្សជីវចម្រុះ ការដាំព្រៃឈើឡើងវិញ ការរៀបចំសហគមន៍ព្រៃឈើ ការកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ និងការចាត់វិធានការទប់ស្កាត់បង្ក្រាប និងលុបបំបាត់ការដុតរានឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃធ្វើជាកម្មសិទ្ធិឯកជន ។

រដ្ឋាភិបាល ចាត់ទុកសហគមន៍ព្រៃឈើ ជាការងារអាទិភាពក្នុងការគ្រប់គ្រងព្រៃឈើ ។ រដ្ឋាភិបាល លើកទឹកចិត្តដល់វិស័យឯកជន ក្នុងការដាំដុះព្រៃឯកជន ដែលមានលក្ខណៈសេដ្ឋកិច្ច ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ ជាពិសេសក្នុងតំបន់ព្រៃឈើរេចរិល ។

# គ. យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ឆ្នាំ២០១៨




## មុំទី២. ការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ ប្រកបដោយចីរភាព

**ទី៣.** បន្តគ្រប់គ្រងធនធានព្រៃឈើ និងសត្វព្រៃ ដោយថែរក្សាគម្របព្រៃឈើ **ឱ្យលើសពី ៦០% នៃផ្ទៃប្រទេស**, ការលើកកម្ពស់ការអភិរក្សព្រៃឈើ និងសត្វព្រៃ, ការទប់ស្កាត់ការទន្ទ្រានកាន់កាប់ និងឈូសឆាយដីព្រៃធ្វើជាកម្មសិទ្ធិ, ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការការពារ និងស្តារព្រៃឈើឡើងវិញ ព្រមទាំងការបង្ក្រាបបទព្រៃឈើ និងការជួញដូរសត្វព្រៃ ។

**ទី៤.** ការបន្តជំរុញការអភិរក្ស និងគ្រប់គ្រងធនធានជលផល តាមរយៈការបង្ក្រាបបទល្មើសជលផល, ការធ្វើឡើងឱ្យប្រសើរឡើងនូវសហគមន៍នេសាទ និងការបង្កើនវារីវប្បកម្ម ។

**ទី៥.** លើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និងការការពារតំបន់ធម្មជាតិ ដោយផ្តោតលើការការពារជីវចម្រុះ តំបន់ដីសើម និងតំបន់ឆ្នេរ ដើម្បីធានាគុណភាពដី ចរីភាពប្រភពទឹក ។

យុទ្ធសាស្ត្រចតុកោណ
ដំណាក់កាលទី៤

ឆ្នាំ ២០១៨

## គ. ៥. គោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលការពារធនធានធម្មជាតិ

### គ. កម្មវិធីព្រៃឈើជាតិ ឆ្នាំ២០១០ . ២០២៩



ឆ្នាំ ២០១០

**មានទិសស្លោក៖** “និរន្តរភាពព្រៃឈើសម្រាប់ប្រជាជនយើង”

**ទស្សនវិស័យ៖** ការគ្រប់គ្រងធនធានព្រៃឈើដែលធានានិរន្តរភាពអេកូឡូស៊ី សេដ្ឋកិច្ច-សង្គម វប្បធម៌ និងបរិស្ថាន គឺជាមូលដ្ឋានគ្រឹះនៃសុខុមាលភាពសាធារណៈ។

**បេសកកម្ម៖** ជម្រុញឲ្យមានការគ្រប់គ្រង និងការអភិវឌ្ឍព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ជីវភាពរស់នៅ ការអភិវឌ្ឍសេដ្ឋកិច្ច ការការពារបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះ និងមរតកវប្បធម៌របស់យើង។

**ចំណុច.៣ នៃទំព័រ៣០៖** សូចនាករ រដ្ឋាភិបាលបានប្តេជ្ញាថានឹងបង្កើនគម្របព្រៃឈើឱ្យ**បាន៦០%ត្រឹមឆ្នាំ២០២៩**។

# ត. ៥. គោលនយោបាយ និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលការពារធនធានធម្មជាតិ

## គោលនយោបាយបន្ថែម ពីកិច្ចការពារធនធានធម្មជាតិ



១.គោលនយោបាយជាតិ ស្តីពី ការអភិវឌ្ឍបៃតង (២០១៣)

២. ផែនការយុទ្ធសាស្ត្រជាតិ ស្តីពី ការអភិវឌ្ឍបៃតង (២០១៣-២០៣០)

៣. ផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (២០១៤-២០២៣)

៤. ផែនការសកម្មភាពជាតិ និងផែនការសកម្មភាពបរិស្ថានឆ្នាំ ២០១៦-២០២៣







# គោលនយោបាយរដ្ឋាភិបាល គ្រប់គ្រងធនធានធម្មជាតិ ជារួម៖

រដ្ឋាភិបាលកម្ពុជាបាន ប្ដេជ្ញារក្សាគម្របព្រៃឈើ **៦០%** នៃផ្ទៃប្រទេស

១ យុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី២ ឆ្នាំ២០០៨ និងទី៤ ឆ្នាំ២០១៨

២ កម្មវិធីព្រៃឈើជាតិ ឆ្នាំ២០១០.២០២៩

៣ សន្និសីទអង្គការសហប្រជាជាតិ ស្ដីការប្រែប្រួលអាកាសធាតុ នៅទីក្រុង ប៉ារីស(PARIS COP21-2015)

# ព្យុះគំនិត៖

សាកល្បងប៉ាន់ប្រមាណមើល ថាតើការប្ដេជ្ញាចិត្តទាំងនោះ តើរាជរដ្ឋាភិបាលអាចសម្រេចបានដែរ ឬទេ? ហេតុអ្វី?

(៥នាទី)

# ៤. ស្ថានភាពធនធានធម្មជាតិ នៅកម្ពុជា




*ក្រាហ្វិច បង្ហាញពីការប្រែប្រួលគម្របព្រៃឈើនៅប្រទេសកម្ពុជា ចាប់ពីឆ្នាំ ១៩៦៥-២០១៨*

*ដែលបានចុះផ្សាយដោយក្រសួងបរិស្ថាន លើរបាយការណ៍ស្ថានភាពបរិស្ថាន លើកទី៤ ឆ្នាំ ២០២១*



# យល់ឬ
# មិនយល់



# ទោះយល់ ឬមិនយល់
# សូមបញ្ចប់តែប៉ុណ្ណោះ!

# សូមអរគុណ!

# ICON PACK

